ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ២៦៩ /២០-៤-២០០៦

សាលដីកា

លេខ : ៩៦ "ជ"/១១-៦-២០០៩

<u>តាងនាមប្រជារាស្ត្រខ្មែរ</u>

<u>សាលាឧទ្ធរណ៍ភ្នំពេញ</u>

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី ០៩ កុម្ភៈ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ កាលពីថ្ងៃទី ១១-៦-២០០៩ ដែលមានសមាសភាពដូចខាងក្រោមនេះ

<u>ក្រុមប្រឹក្សាជំនុំជំរះ</u>

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រម

លោក [redacted] ជាចៅក្រម

<u>តំណាងមហាអយ្យការ</u>

លោក [redacted]

<u>ក្រឡាបញ្ជី</u>

លោកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ : ២៦៩ ចុះថ្ងៃទី ២០-៤-២០០៦ រវាង :

១- ជនជាប់ចោទឈ្មោះ[redacted]ឃ្លីម ហៅ ពាង ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅភូមិអណ្តូង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល របររកស៊ីនេសាទត្រី មាន[redacted] ស្រុកស្អាង ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]"ស" ម្តាយឈ្មោះ [redacted]" នៅលីវ កំរិតវប្បធម៌ ថ្នាក់ទី៤ ថ្មី ។ ចាប់ខ្លួនថ្ងៃទី២៨-៤-២០០៥ , ឃុំខ្លួនថ្ងៃទី២៩-៤-២០០៥ ។

២- ជនជាប់ចោទ ឈ្មោះ [redacted]ល្លា ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើត និងរស់នៅភូមិសិត្បូ [redacted] របររកស៊ីមិនពិតប្រាដក ឪពុកឈ្មោះ នី "រ" ម្តាយឈ្មោះ ធូ "រ" ប្រពន្ធឈ្មោះ [redacted] ទោសពីមុន គ្មាន ។ " ដើមបណ្តឹងឧទ្ធរណ៍ " ចាប់ខ្លួនថ្ងៃទី ២២-១០-២០០៥ , ឃុំខ្លួនថ្ងៃទី ២៤-១០-២០០៥ ។

៣- ជនជាប់ចោទឈ្មោះ[redacted]វី ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើត និងរស់នៅភូមិ



Scanned with CamScanner

[redacted]ង ខេត្តកណ្តាល របររកស៊ីមិនពិតប្រាដក ឪពុក[redacted]រ៉ ម្តាយ ឈ្មោះ [redacted]រ៉ នៅលីវ ទោសពីមុនគ្មាន ករិតវប្បធម៌ ថ្នាក់ទី១ថ្មី ។ ( គេចខ្លួន )

៤- ជនជាប់ចោទឈ្មោះ [redacted] ហើម ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើត និង រស់នៅ[redacted] ខេត្តកណ្តាល របររកស៊ីមិនពិតប្រាដក ឪពុក ឈ្មោះ [redacted]រ៉ ម្តាយឈ្មោះ [redacted]រ៉ នៅលីវ ទោសពីមុនគ្មាន ។ " ដើមបណ្តឹងឧទ្ធរណ៍ " ឃុំខ្លួនថ្ងៃទី ០៨-១២-២០០៦ ។

ត្រូវចោទពីបទ : **ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ( ម៉ូតូ )** ប្រព្រឹត្តនៅភូមិទួលក្រាំង ឃុំក្រាំងយ៉ូវ ស្រុកស្អាងខេត្តកណ្តាល កាលពីថ្ងៃទី ២៨-៤-២០០៥ បទល្មើសព្រហ្មទណ្ឌ ដែលមានបញ្ញត្តិឲ្យផ្តន្ទាទោស តាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

- ជនរងគ្រោះឈ្មោ[redacted]ភន ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ីយោធា ទីលំនៅសព្វថ្ងៃ នៅភូមិទួលក្រាំង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល ។ " ចុងបណ្តឹងឧទ្ធរណ៍ "

**ឯរឿងហេតុមានដូចតទៅ :**

កាលពីថ្ងៃទី ២៨-៤-២០០៥ វេលាម៉ោងប្រហែល ១៩និង៤០នាទី នៅភូមិទួលក្រាំង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល មានករណីប្លន់ម៉ូតូមួយ បានកើតឡើងដោយជនល្មើសមួយក្រុម មានគ្នា ០៤នាក់ ឈ្មោះ [redacted]ឃ្លឹម ហៅ ពាង ភេទប្រុស អាយុ ១៨ឆ្នាំ , ឈ្មោ[redacted]ពុំណ្ណា ភេទប្រុស អាយុ ២៤ឆ្នាំ , ឈ្មោះ [redacted]រី ភេទប្រុស អាយុ ២៤ឆ្នាំ , និងឈ្មោះ[redacted] ហើម ភេទប្រុស អាយុ ១៨ឆ្នាំ បានស្ទាក់ប្លន់ម៉ូតូ ឈ្មោះ [redacted] ភន ដោយយកកាំបិតផ្គាក់ និងដាវកាប់ទៅលើជនរងគ្រោះ បណ្តាលអោយមានរបួសត្រូវចំកំភួនជើង និងមួយផ្គាក់ទៀត ត្រូវជិតកញ្ចឹងក បន្ទាប់មកក្រុមជនល្មើស ក៏បានយកម៉ូតូម៉ាកយ៉ាម៉ាណា ស្លាប ពណ៌ខៀវលាយទឹកប្រាក់ ជិះគេចខ្លួនតែម្តង ។ លុះក្រោយមកសមត្ថកិច្ច ចាប់ខ្លួនឈ្មោះ[redacted]ឃ្លឹម បានតែម្តង ឯជនល្មើសបីនាក់ទៀតបានរត់គេច ខ្លួនបាត់ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌ លេខ : ៣០ " ថ " ចុះថ្ងៃទី ២៣-៩-២០០៥ ដែលមានខ្លឹមសារដូចតទៅ :

**១- ផ្តន្ទាទោស :**

ក- ផ្តន្ទាទោសជនជាប់ចោទ ឈ្មោះ[redacted]ឃ្លឹម ហៅ ពាង ហៅ ឈឹន ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ " ប្រាំបី " គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី ២៨-៤-២០០៥ ។

ខ- ផ្តន្ទាទោសជនជាប់ចោទ ឈ្មោះ[redacted]ពុំណ្ណា ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ "ដប់" គិតពីថ្ងៃចាប់ខ្លួនបាន ។

គ- ផ្តន្ទាទោសជនជាប់ចោទ ឈ្មោ[redacted]រី ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ "ដប់" គិតពីថ្ងៃចាប់ខ្លួនបាន ។

ឃ- ផ្តន្ទាទោសជនជាប់ចោទ ឈ្មោះ [redacted]ហើម ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់ ០៨ឆ្នាំ "ប្រាំបី" គិតពីថ្ងៃចាប់ខ្លួនបាន ។

ជាប់ចោទពីបទ : **ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ( ម៉ូតូ )** ប្រព្រឹត្តនៅ ភូមិទួលក្រាំង ឃុំក្រាំងយ៉ូវ ស្រុកស្អាង



Scanned with CamScanner

ខេត្តកណ្តាល កាលពីថ្ងៃទី ២៨-៤-២០០៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២- បង្គាប់ឱ្យ ជនជាប់ចោទឈ្មោះ [redacted] ឃ្លីម ហៅ ពាង ហៅ លីន , ជនជាប់ចោទឈ្មោ [redacted] ភេទប្រុស , ជនជាប់ចោទឈ្មោះ [redacted] រី និងជនជាប់ចោទឈ្មោះ [redacted] ហ៊ីម រួមគ្នាសងជម្ងឺចិត្ត និងថ្លៃព្យាបាលរបួសចំនួន ៤០០០.០០០រៀល (បួនលានរៀល) ឱ្យទៅជនរងគ្រោះ ឈ្មោះ [redacted] ភន សំណើរលើសពីនេះ ត្រូវលើកចោល ។ ក្នុងករណីជនជាប់ចោទ គ្មានប្រាក់សង ត្រូវចាប់ដាក់គុកបង្ខំរូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ។

៣- វត្ថុតាង : មានម៉ូតូម៉ាក ស៊ុយស៊ូគី គូរ៉េ ពណ៌ក្រហម ០១គ្រឿង ជាមធ្យោបាយ ប្រព្រឹត្តបទល្មើស ត្រូវរឹបអូសទុកជា សម្បត្តិរដ្ឋ ។

៤- សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted] ឃ្លីម ហៅ ពាង ហៅ លីន និងជនរងគ្រោះ ឈ្មោះ [redacted] ភន កំបាំងមុខជនជាប់ចោទឈ្មោ [redacted] ប៊ុណ្ណា , ឈ្មោះ [redacted] រី , ឈ្មោ [redacted] ហ៊ីម បើកសិទ្ធិ អោយប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញ លិខិតឱ្យដំណឹង ពីសាលក្រមកំបាំងមុខ លេខ : ២១៦ អ.ក ចុះថ្ងៃទី ២៥-៤-២០០៥ របស់តុលាការខេត្តកណ្តាល ប្រាប់មកឈ្មោះ [redacted] ហ៊ីម ឱ្យបានដឹងពី សាលក្រមកំបាំងមុខ លេខ : ៣០ "ថ" ចុះថ្ងៃទី ២៣-៩-២០០៥ ។(ឯ . ១/១)

សាលក្រមនេះ ត្រូវបានឈ្មោ [redacted] ហ៊ីម ប្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៣-០១-២០០៧ ត្រង់ចំណុច នៃសេចក្តីសំរេចទាំងមូល ។

សាលក្រមនេះ ត្រូវបានឈ្មោ [redacted] ប៊ុណ្ណា ប្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៨-០១-២០០៧ ត្រង់ចំណុច នៃសេចក្តីសំរេចនៃទោស ។

- បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ១៧-៨-២០០៧ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍ ចុះថ្ងៃទី ២៦-០២-២០០៨ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] ឃ្លីម ( មិនចូល )
- ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ( មិនចូល )
- ជនជាប់ចោទឈ្មោះ [redacted] ណ្ណា ( មិនចូល )
- មេធាវីការពារជនជាប់ចោទ លោក [redacted] ឃី ( ចូល )
- ជនរងគ្រោះ ឈ្មោ [redacted] ភន ( មិនចូល )

- ប្រធានក្រុមប្រឹក្សា ធ្វើការអធិប្បាយហេតុការណ៍ នៃរឿងដែលកើតមានឡើង និងអានសេចក្តីសំរេចរបស់តុលាការខេត្តកណ្តាល ។

- មេធាវីការពារជនជាប់ចោទ លោក [redacted] ឃី : មិនមានយោបល់អ្វីទេ ។

- **តំណាងមហាអយ្យការ ធ្វើសេចក្តីសន្និដ្ឋាន :** ឃើញថា តាមចម្លើយសារភាព របស់ជនជាប់ចោទ បាន



Scanned with CamScanner

ឆ្លើយថា បក្សពួកខ្លួនបានកាប់ទៅលើ ជនរងគ្រោះមែន ឃើញថាមានភស្តុតាងច្បាស់លាស់ ពីបទ ប្លន់ ដូចក្នុង សេចក្ដីសំអាងហេតុរបស់តុលាការខេត្តកណ្ដាល ។

ហេតុដូចនេះ សូមតម្កល់សាលក្រមព្រហ្មទណ្ឌ លេខ : ៣០ " ថ " ចុះថ្ងៃទី ២៣-៩-២០០៥ នៅដដែល ដោយសុំលុបវិធានអនុវត្តដាក់គុកបង្ការបកាយ ចេញពីសេចក្ដីប្រកាសនៃសាលក្រម តាមមាត្រា ៩២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**- មេធាវីការពារជនជាប់ចោទ ធ្វើសេចក្ដីសន្និដ្ឋាន :** សូមតុលាការពិចារណា ព្រោះជនជាប់ចោទ នៅក្មេងខ្ចី ទើបតែប្រព្រឹត្តបទល្មើសជាលើកទី១ សុំបន្ធូរ បន្ថយទោស ដល់កូនក្ដីខ្ញុំបាទផង ។

- ក្រោយពីបាន អាន និងស្ដាប់ ចម្លើយជនជាប់ចោទ និង ជនរងគ្រោះ ។
- ក្រោយពីបានស្ដាប់តំណាងមហាអយ្យការសន្និដ្ឋាន ។
- ក្រោយពីបានពិនិត្យឯកសារពាក់ពន្ធ័ល្អិតល្អន់ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ។

## សាលាឧទ្ធរណ៍

យល់ឃើញថា :

- បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៣ មករា ២០០៧ របស់ជនជាប់ចោទ ឈ្មោះ [redacted] ហើម និង ចុះថ្ងៃ មករា ២០០៦ របស់ជនជាប់ចោទ ឈ្មោះ [redacted] ណ្ណា ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ១៧ នៃច្បាប់ស្ដីពីនីតិ វិធីព្រហ្មទណ្ឌ និងមាត្រា ៦០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន ។

- មេធាវី [redacted] ឃី ជាមេធាវីការពារអោយជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

- តាមចម្លើយជនរងគ្រោះ ឈ្មោះ [redacted] ភន (ឯ. ២៨/២ )ថា ពេលខ្លួនជិះម៉ូតូមកដល់ទួលក្រាំង មមនុស្ស ៤នាក់ ស្ទាក់ផ្លូវ ហើយស្រែកអោយឈប់ម៉ូតូ ។ ធ្លាវាម្នាក់បានស្រែកថា កាប់វាអោយងាប់ៗ ។ ធ្លាវាចកាប់១ផ្ចាប់ ត្រូវកំភួនជើង និងថែមមួយផ្ចាក់ទៀត ត្រូវជិតកញ្ចឹងក វាស្មានថាស្លាប់ហើយ វាស្រែកអោយឈ្មោះប៊ុណ្ណា លើកម៉ូតូ ។ ពេលប្រជាជនឈូរឆមកមើល ខ្លួនស្គាល់មុខចោរម្នាក់ ឈ្មោះ ហើម វាមកមើលដែរ ខ្លួនអោយអាហើម នៅឱ្យស្ងៀមរង់ចាំ ប៉ូលីសដោះស្រាយ ។ ឈ្មោះនេះគេចខ្លួនភ្លាម ដោយមានឈ្មោះ [redacted] ជួយ ។ រយប់នោះម្ដាយអាហើម បានជូនខ្លួនទៅយកម៉ូតូនៅបូរីកីឡា ។ ឃើញថាចម្លើយជនរងគ្រោះស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទ ឈ្មោះ [redacted] ហ្លឹម ( ឯ . ២៧/២ ) ។

- អំពើពួនស្ទាក់កាប់ទៅលើម្ចាស់ម៉ូតូ ដើម្បីប្លន់ ជាធាតុផ្សំនៃអំពើឃាតកម្មគិតទុកជាមុន ដែលមានចែង និងផ្ដន្ទាទោស តាមមាត្រា ៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ។ គប្បីកែប្រែបទចោទទៅជា ឃាតកម្មគិតទុកជាមុន តែទណ្ឌកម្មទៅលើជនជាប់ចោទ គប្បីរក្សាទុកដដែល ដោយគ្មានបណ្ដឹងឧទ្ធរណ៍ របស់ព្រះរាជអាជ្ញា ។

- សាលក្រមព្រហ្មទណ្ឌ លេខ ៣០ "ថ" ចុះថ្ងៃ ២៣-៩-២០០៥ របស់សាលាដំបូង ខេត្តកណ្ដាល មានលក្ខណៈត្រឹមត្រូវ លើកលែងតែបទចោទ ត្រូវកែប្រែតាមការយល់ឃើញខាងលើ ។

## ហេតុដូចនេះវិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃ០៣ មករា ២០០៧ របស់ជនជាប់ចោទ [redacted] ហើម និង ចុះថ្ងៃ០៨ មករា ២០០៦ របស់ជនជាប់ចោទ ឈ្មោះ [redacted] ប៊ុណ្ណា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោល ដោយទាស់គតិច្បាប់

២- តម្កល់ សាលក្រមព្រហ្មទណ្ឌ លេខ : ៣០ "ថ" ចុះថ្ងៃទី ២៣- ៩- ២០០៥ របស់សាលាដំបូង ខេត្តកណ្តាល ទុកជាបានការ ដោយគ្រាន់តែកែប្រែបទចោទពីបទ : ប្លន់ ទៅជា ឃាតកម្មគិតទុកជាមុន វិញ ។ ចំណុចផ្សេងទៀត ទុកជាបានការដដែល ។

- លុបចោលវិធាន អនុវត្តដាក់គុក បង្ខំរូបកាយ ចេញពីសេចក្តីប្រកាស នៃសាលក្រម តាមមាត្រា ៥២៤ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣- បន្តឃុំខ្លួន ជនជាប់ចោទ ឈ្មោ[redacted]ប៊ុណ្ណា [redacted] ហើម តាមមាត្រា ៣៥៣ និង ៤០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវី កំបាំងមុខជនជាប់ចោទ ។

បើកផ្លូវ ប្តឹងតវ៉ា តាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្ត សាលដីកា ស្ថាប័នមានសមត្ថកិច្ច គ្រប់ថ្នាក់គ្រប់ដែនដី និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្ត សាលដីកានេះឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេ[redacted] | ហត្ថលេខា[redacted] [redacted] | ហត្ថលេខា[redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
សាលាឧទ្ធរណ៍ . ថ្ងៃទី.29..ខែ ឧ.ស.ភា.ឆ្នាំ ២០.15
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner